# ជំណាំស្រូវនៅកម្ពុជា



ពិនិត្យដោយ បណ្ឌិត ម៉ែន សារុម

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

# អារម្ភកថា

ស្រូវគឺជាដួងព្រលឹងនៃជនជាតិខ្មែរ។ ដំណាំស្រូវបានចាក់ឫសយ៉ាងជ្រៅទៅក្នុងផ្នត់គំនិត អារម្មណ៍ និងបានផ្សារ ភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងវប្បធម៌ ប្រពៃណី ទំនៀមទំលាប់ របស់ប្រជាជាតិកម្ពុជាតាំងពីយូរលង់ណាស់មកហើយ។ ចំពោះប្រជាកសិករខ្មែរ ស្រូវមិនត្រឹមតែជាពូជដំណាំសាមញ្ញមួយតែប៉ុណ្ណោះទេ តែគឺជាវប្បធម៌ សាសនា និងនយោបាយ។ ពាក្យទំនៀម សុភាសិត ពាក្យកាព្យ និងការលេងល្បែងផ្សេងៗរបស់បុព្វបុរសខ្មែរបាន យកស្រូវ ឬដំណាំស្រូវមកធ្វើជាមូលដ្ឋាន។ បន្ថែមលើនេះពិធីបុណ្យផ្សេងៗមួយចំនួនដែលរៀបចំប្រារព្ធឡើងក៏ដើម្បីឧទ្ទិសដល់ដំណាំស្រូវ និងត្រូវបាន ទទួលស្គាល់ជាទូទៅផងដែរថាស្រូវ គឺជាម្តាយ ឬជាអាទិទេពដែលផ្តល់ជីវិត និងថាមពលសម្រាប់ជាការរស់រានដល់ មនុស្សជាតិទាំងឡាយ។ "មានស្រូវ គឺមានអ្វីៗ ទាំងអស់" នេះគឺជាពាក្យស្លោកមួយដែលបានបង្ហាញយ៉ាងប្រត្យក្ស អំពីឥទ្ធិពលនៃដំណាំស្រូវចំពោះមូលដ្ឋានសេដ្ឋកិច្ចគ្រួសារ ក៏ដូចជាសេដ្ឋកិច្ចនិងនយោបាយជាតិ។ ជាក់ស្តែងការឈានឡើងដល់កំពូលនៃអាណាចក្រខ្មែរសម័យអង្គរ គឺពិតជាមានការចូលរួមចំណែកយ៉ាងធំធេងពីដំណាំស្រូវ ទៅលើ សេដ្ឋកិច្ចនិងនយោបាយជាតិខ្មែរសម័យនោះ។

ប៉ុន្តែជាការមួយគួរឱ្យសោកស្តាយដោយសារៈកន្លងមក បទពិសោធន៍ និងចំណេះដឹងទាំងឡាយអំពីដំណាំស្រូវ និងការធ្វើវប្បកម្មលើដំណាំនេះ ដែលទាំងនេះគឺជាទ្រព្យសម្បត្តិរបស់អ្នកបុព្វការីជនជាតិ និងប្រជាកសិករយើង រាប់សតវត្ស មិនត្រូវបានចងក្រងជាឯកសារសម្រាប់ទុកចែកជូនដល់កូនចៅជំនាន់ក្រោយឡើយ។ ផ្ទុយទៅវិញអត្ថបទ អំពីដំណាំស្រូវបានត្រូវបានបោះពុម្ពផ្សាយជាបន្តបន្ទាប់ ដោយអ្នកវិទ្យាសាស្ត្របរទេស ដែលមិនមានប្រពៃណីជាប់ជំពាក់ ជាមួយដំណាំស្រូវនេះទៅវិញ។

ដូច្នេះនេះគឺជាកិត្តិយស និងមោទនភាពដ៏ធំធេងដែលសៀវភៅស្តីពីដំណាំស្រូវនៅកម្ពុជា ត្រូវបានរៀបចំចងក្រង និងសរសេរឱ្យប្រសព្វព្រមពេញជាប្រព័ន្ធឡើងពីស្នាដៃអ្នកស្រាវជ្រាវខ្មែរសុទ្ធសាធ។ ទាំងនេះគឺជាសមិទ្ធិផលនៃការខំប្រឹងប្រែងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ ពោរពេញទៅដោយឆន្ទៈស្នេហាជាតិ ស្មារតីទទួលខុសត្រូវ និងប្រកប ដោយការយល់ឃើញយ៉ាងត្រឹមត្រូវ នូវសារសំខាន់ដែលចាំបាច់ឱ្យមានឯកសារស្តីអំពីដំណាំស្រូវ ជាខេមរភាសា ដោយអ្នកស្រាវជ្រាវនៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា សម្រាប់បំពេញនូវភាពស្រេកឃ្លានចំណេះដឹងរបស់កូនខ្មែរទូទៅ។

ដើម្បីសម្រួលដល់ការសិក្សា និងការចាប់យកឱ្យបានជាអតិបរិមានូវខ្លឹមសារអត្ថបទដែលមានអ្នកនិពន្ធបាន ចែកសៀវភៅ "ដំណាំស្រូវនៅកម្ពុជា" នេះជា ១២ជំពូកគឺ

- ជំពូកទី ១ ប្រវត្តិនៃវប្បកម្មដំណាំស្រូវនៅកម្ពុជា
- ជំពូកទី ២ បរិស្ថាននៃដំណាំស្រូវ
- ជំពូកទី ៣ លក្ខណៈរុក្ខសាស្ត្រនៃដំណាំស្រូវ
- ជំពូកទី ៤ សរីរៈសាស្ត្រនៃដំណាំស្រូវ

- ជំពូកទី ៥ ពន្ធុវិទ្យា និង បរិសុទ្ធកម្មពូជ
- ជំពូកទី ៦ ប្រព័ន្ធក្សេត្របរិស្ថាន និងវប្បកម្មដំណាំស្រូវនៅកម្ពុជា
- ជំពូកទី ៧ ប្រព័ន្ធកសិកម្មដែលមានដំណាំស្រូវជាមូលដ្ឋាន
- ជំពូកទី ៨ ដី និងការគ្រប់គ្រងសារធាតុចិញ្ចឹមសម្រាប់ដំណាំស្រូវ
- ជំពូកទី ៩ កត្តាចង្រៃ និងការគ្រប់គ្រង
- ជំពូកទី ១០ ការប្រមូលផល និងទុកដាក់
- ជំពូកទី ១១ សេដ្ឋកិច្ច និងទីផ្សារ
- ជំពូកទី ១២ អត្ថប្រយោជន៍នៃដំណាំស្រូវ

ប៉ុន្តែទោះបីជាមានការប្រឹងប្រែង និងយកចិត្តទុកដាក់លើការរៀបចំយ៉ាងណាក្តី ក៏មិនអាចជៀសផុតបានពីកំហុសឆ្គងដោយប្រការណាមួយដែរ ដូច្នេះយើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការដឹងគុណ នូវរាល់ការចង្អុលបង្ហាញ និងការផ្តល់មតិកែលម្អទាំងឡាយដែលអាចមាន ទោះជារាល់ការរៀបចំក្តី ឬខ្លឹមសារនៃអត្ថបទក្តី ដើម្បីជាផលប្រយោជន៍ដល់ខេមរបុត្រគ្រប់រូប។ ខ្ញុំក៏សូមសម្តែងនូវអំណរគុណជាអនេកផងដែរ ដល់ការគាំទ្រជាថវិកាពីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) អង្គការកសិកម្ម និងស្បៀងអាហារពិភពលោក (FAO) មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) និងគម្រោង LEARN-IT នៅកម្ពុជា សម្រាប់ការបោះពុម្ពនូវសៀវភៅនេះឡើង។

ភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៧

នាយកវិទ្យាស្ថាន

ម៉ែន សារុម

# មាតិកា

ទំព័រ


អារម្ភកថា ........................................ ៧

ជំពូកទី១ : ប្រវត្តិនៃការដាំដុះដំណាំស្រូវនៅកម្ពុជា (ម៉ែន សារុម, នេស ប៊ីតា និងជេម្ស គិបផុយ) ១

១.១- ស្រូវ និងមនុស្ស ........................................ ១

១.២- ប្រវត្តិនៃវប្បធម៌ដាំស្រូវនៅកម្ពុជា ........................................ ៥

១.៣- ស្ថានភាពផលិតកម្មដំណាំស្រូវ ........................................ ១១

ជំពូកទី២ : បរិស្ថាននៃដំណាំស្រូវ (ព្រាប វិសារ៉ា) ........................................ ២១

២.១- សេចក្តីផ្តើម ........................................ ២១

២.២- សីតុណ្ហភាព ........................................ ២១

២.៣- ពន្លឺ ........................................ ២៣

២.៤- ទឹក ........................................ ២៤

២.៥- សារធាតុចិញ្ចឹមនៃដំណាំស្រូវ ........................................ ២៦

ជំពូកទី៣ : លក្ខណៈរូបសាស្ត្រនៃដំណាំស្រូវ (អ៊ុក ម៉ាកា, ពិន ថាវ និងឡោ ប៊ុណ្ណា) ........................................ ៣០

៣.១- លក្ខណៈរូបសាស្ត្រនៃសរីរាង្គលូតលាស់ ........................................ ៣០

៣.២- លក្ខណៈរូបសាស្ត្រនៃសរីរាង្គបន្តពូជ ........................................ ៣៤

ជំពូកទី៤ : សរីរៈសាស្ត្រនៃដំណាំស្រូវ (អ៊ុក ម៉ាកា, ឡោ ប៊ុណ្ណា និងមិន ចរិយា) ........................................ ៤២

៤.១- សរីរៈសាស្ត្រនៃដំណុះគ្រាប់ ........................................ ៤២

៤.២- សរីរៈសាស្ត្រនៃដំណេកគ្រាប់ ........................................ ៤៨

៤.៣- ការបង្កបង្កើតកូនពន្លកថែម ........................................ ៥២

៤.៤- សរីរៈសាស្ត្រនៃការចេញផ្កា ........................................ ៥៥

៤.៥- សរីរៈសាស្ត្រនៃភាពទុំ ........................................ ៦០

៤.៦- ទុតាទិសរីរៈនៃដំណាក់កាលលូតលាស់ ........................................ ៦៨

៤.៧- រស្មីសំយោគ និងដំណើរការបង្កើតនៅក្នុងស្លឹក ........................................ ៧០

ជំពូកទី៥ : ពន្ធុសាស្ត្រ និងបង្កាត់ពូជ (ម៉ែន សារុម និងភិត ខុមវីហ៊ៀង) ........................ ៧៨

៥.១- ពន្ធុសាស្ត្រនៃដំណាំស្រូវ ........................ ៧៨

៥.២- ជំរើសពូជនៃដំណាំស្រូវ ........................ ១០៦

៥.៣- ផលិតកម្មគ្រាប់ពូជសុទ្ធ ........................ ១២៣

ជំពូកទី៦ : ប្រព័ន្ធអេកូបរិស្ថាន និងបច្ចេកទេសដំណាំស្រូវនៅកម្ពុជា (សាខន សុផានី, ម៉ាង ស៊ីហេង ឡេង ឡាយហុង និងចេង រ៉ត្ន) ........................ ១៣៤

៦.១- សេចក្តីផ្តើម ........................ ១៣៤

៦.២- អេកូបរិស្ថានទូទៅ ........................ ១៣៧

៦.៣- ប្រព័ន្ធអេកូបរិស្ថានស្រូវស្រែទំនាបអាស្រ័យទឹកភ្លៀង ........................ ១៤២

៦.៤- ប្រព័ន្ធអេកូបរិស្ថានស្រូវទឹកជ្រៅ ........................ ១៥១

៦.៥- ប្រព័ន្ធអេកូបរិស្ថានស្រូវចំការ ........................ ១៥៥

ជំពូកទី៧ : ប្រព័ន្ធកសិកម្មដែលមានដំណាំស្រូវជាមូលដ្ឋាន (ភាវ សុវុទ្ធិ, ចាន់ ផលឿង, អ៊ុង សុភាព និង ឆាង សាវុឌ្ឍី) ........................ ១៦៣

៧.១- ប្រព័ន្ធកសិកម្ម និងរបបទឹកភ្លៀង ........................ ១៦៤

៧.២- ប្រព័ន្ធកសិកម្ម និងវិធីដាំដុះដំណាំ ........................ ១៦៦

៧.៣- ប្រព័ន្ធដាំដុះដំណាំ ........................ ១៦៨

៧.៤- ប្រព័ន្ធកសិកម្មចំរុះ ........................ ១៧២

៧.៥- ការចែករកសិក្សាមនុស្ស ........................ ១៨០

ជំពូកទី៨ : ដី និងការគ្រប់គ្រងសារធាតុចិញ្ចឹមសម្រាប់ដំណាំស្រូវ (សេង វ៉ាង, ភាវ សុវុទ្ធិ, ប៊ុន សាបិត, ពូរ ច័ន្ទរ៉ា និង ឌួច វ៉ាសនា) ........................ ១៨៧

៨.១- ដីដាំដំណាំស្រូវនៅកម្ពុជា ........................ ១៨៧

៨.២- ការគ្រប់គ្រងជីធាតុជី ........................ ២០៦

៨.៣- បញ្ហាដី និងការគ្រប់គ្រង ........................ ២១៨

ជំពូកទី៩ : ស្មៅចង្រៃ និងការគ្រប់គ្រង (ព្រាប វិសារទោ, មិ វុទ្ធិ, ប៊ុល ចាន់ធី និងខៀវ បុណ្ណារិទ្ធ) ........................ ២២៨

៩.១- ជីវិតដើមដំណាំស្រូវ ........................ ២២៨

៩.៧- សត្វល្អិតស៊ីស្រូវ ........................................ ២៥១

៩.៨- ស្មៅសំខាន់ៗនៅលើដំណាំស្រូវ ........................................ ២៦០

ជំពូកទី១០ : ការប្រមូលផល និងទុកដាក់ (សោម ប៊ុណ្ណា, នៅ ស៊ីណាត និងហ៊ួន សេរីវុធ) ........................................ ២៦៧

១០.១- ការច្រូតកាត់ ........................................ ២៦៧

១០.២- ការបោកបែន ........................................ ២៧៨

១០.៣- ការសម្ងួត ........................................ ២៨០

១០.៤- ការទុកដាក់ ........................................ ២៨៥

ជំពូកទី១១ : សេដ្ឋកិច្ច និងទីផ្សារ (ជា សារ៉េត) ........................................ ២៩៨

១១.១- ផលសំខាន់នៃដំណាំស្រូវ ........................................ ២៩៨

១១.២- ថ្លៃដើមផលិតកម្មស្រូវ ........................................ ២៩៩

១១.៣- ប្រែប្រួលនៃការកាន់កាប់ដី និងផលិតកម្មស្រូវនៅកម្ពុជា ........................................ ៣០២

១១.៤- កត្តាសំខាន់ៗសម្រាប់ការវិភាគផលិតកម្មស្រូវ ........................................ ៣០៧

១១.៥- ឥទ្ធិពលនៃបច្ចេកវិទ្យាលើសេដ្ឋកិច្ច ........................................ ៣១០

១១.៦- ការវិភាគសេដ្ឋកិច្ចនៃប្រព័ន្ធដាំដុះស្រូវបីចំណាត់ ........................................ ៣១៥

១១.៧- ការកែច្នៃ និងប្រើប្រាស់ផលិតផល ........................................ ៣២១

១១.៨- ទីផ្សារស្រូវ អង្ករ ........................................ ៣២៤

ជំពូកទី១២ : អត្ថប្រយោជន៍នៃដំណាំស្រូវ (ទី ចាន់ណា, ចាន់សារឿន និងបាក់ សុជាតា)...... ៣៣១

១២.១- ដំណាំស្រូវ និងវប្បធម៌ ........................................ ៣៣៦

១២.២- ដំណាំស្រូវ និងសេដ្ឋកិច្ច និងសង្គម ........................................ ៣៣៧

១២.៣- ដំណាំស្រូវ និងបរិស្ថាន ........................................ ៣៤០

១២.៤- ដំណាំស្រូវ និងទេសចរណ៍ ........................................ ៣៤១

ប្រវត្តិរូបសង្ខេបនៃអ្នកនិពន្ធ ........................................ ៣៤៥

# ជំពូកទី ១

## ប្រវត្តិនៃផលិតកម្មដំណាំស្រូវនៅកម្ពុជា

ម៉ែន សារុម, ឆាយ លីណា និងវេង គីមឆ៊ុយ

### ១.១- ស្រូវ និងមនុស្ស

ស្រូវមានតួនាទីយ៉ាងសំខាន់ ក្នុងការទ្រទ្រង់ដល់ការរស់រានមានជីវិត សម្រាប់ប្រជាពលរដ្ឋប្រមាណជិតពាក់កណ្ដាលនៅក្នុងពិភពលោក ស្ទើរទាំងស្រុងនៅទ្វីបអាស៊ី និងជាអាហារចម្បង និងចាំបាច់បំផុតសម្រាប់ប្រទេសកម្ពុជា។ សម្រាប់ប្រជាពលរដ្ឋកម្ពុជា ស្រូវអង្ករ ឬបាយគឺជាប្រភពផ្ដល់ថាមពលរហូតដល់ប្រមាណពី ៦០ ទៅ ៧០ ភាគរយនៃបរិមាណកាឡូរីចាំបាច់។ នាឆ្នាំ ២០០៤ តម្រូវការអង្ករប្រចាំឆ្នាំ សម្រាប់ប្រជាពលរដ្ឋកម្ពុជាម្នាក់ៗ មានចំនួនប្រមាណ ១៤៣ គីឡូក្រាម ដែលនេះជាបរិមាណច្រើនជាងគេលេខបី បន្ទាប់ពីប្រទេសភូមា និងឡាវ ។

សម្រាប់ប្រទេសកម្ពុជា ស្រូវ គឺជាដំណាំមួយដ៏សំខាន់នៅក្នុងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ ដោយដំណាំនេះ បានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងសេដ្ឋកិច្ច វប្បធម៌ ប្រពៃណី និងទំនៀមទំលាប់របស់ជាតិសាសន៍យើង តាំងតែពីអតីតកាលដ៏យូរលង់ណាស់មកហើយ ។ ភស្តុតាងជាច្រើនបានបញ្ជាក់ថា ទាំងនាពេលបច្ចុប្បន្ន និងទាំងនាពេលអតីតកាល ស្រូវគឺជាដំណាំសេដ្ឋកិច្ចរបស់ជាតិ។ ជាក់ស្ដែងនាសម័យអង្គរ អាស្រ័យដោយមានការចូលរួមចំណែកដ៏ធំធេង និងសំខាន់ពីដំណាំស្រូវ ប្រទេសកម្ពុជានាសម័យនោះបានឈានដល់យុគមាស និងជាអាណាចក្រដ៏ខ្លាំងជាងគេនៅអាស៊ីអាគ្នេយ៍។ អាងបារាយណ៍ទឹកថ្លា ដែលជាស្នាដៃវិស្វកម្មធារាសាស្ត្រដ៏ធំសំបើមមួយ នៅខេត្តសៀមរាប និងដែលត្រូវបានស្ថាបនាឡើងតាំងនៅក្នុងរវាងសតវត្សទី១១ ក៏ជាសក្ខីភាពបញ្ជាក់អំពីគម្រោងការ និងភាពច្នៃប្រឌិតដ៏សំរើករបស់បុព្វបុរសខ្មែរ ដែលបានយល់ច្បាស់អំពីសារសំខាន់ និងឥទ្ធិពលនៃដំណាំស្រូវទៅលើសេដ្ឋកិច្ចជាតិ ហើយបានប្រើប្រែប្រួលយ៉ាងប៉ិនប្រសប់ និងជោគជ័យក្នុងការជម្រុញដល់ការបង្កើនផលិតកម្មដំណាំស្រូវ តាមរយៈការដោះស្រាយបញ្ហាទឹកជាមូលដ្ឋាន ។ ឥទ្ធិពលនៃដំណាំស្រូវនៅក្នុងសង្គមខ្មែរ បានឆ្លុះបញ្ចាំងផងដែរ នៅក្នុងកម្រងអត្ថបទអក្សរសិល្ប៍ជាតិ តាមរយៈរឿងព្រេង រឿងជាតក ឬក៏រឿងប្រលោមលោកនានា ដែលស្ទើរគ្រប់អត្ថបទទាំងអស់ គឺបានរៀបរាប់អំពីបញ្ហាពិតក្នុងសង្គមខ្មែរ អំពីទំនាក់ទំនងនៃសាច់រឿងទៅនឹងដំណាំស្រូវ ក៏ដូចជាបង្ហាញពីផលប្រយោជន៍ នៃដំណាំស្រូវទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ តាំងពីបុរាណកាលមកទល់នឹងពេលបច្ចុប្បន្ន។ ជាឧទាហរណ៍រឿងទុំទាវដែលរៀបរៀងដោយ ព្រះបទុមត្ថេរសោម នា គ.ស ១៩១៥ ត្រូវនឹងព.ស ២៤៥៨ ក៏បានបង្ហាញផងដែរអំពីជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរទាំងគ្រហស្ថ ទាំងសង្ឃ ទាក់ទងទៅនឹងការងារដាំដុះដំណាំស្រូវ និងការធ្វើសក្ការៈសម្រាប់ទុកដាក់ផលស្រូវនៅរដូវច្រូតកាត់ ដូចជាការធ្វើពោកលក់របស់នេនទុំ និងនេនពេជនៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមជាដើម។ នៅក្នុងរឿងផ្កាស្រពោនដែលបាននិពន្ធដោយលោក នូ ហាច នា គ.ស ១៩៤០ ត្រូវនឹង ព.ស ២៤៨០ ក៏បានបង្ហាញផងដែរអំពីការរស់នៅរបស់ប្រជាពលរដ្ឋខ្មែរ